# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

## <u>សេចក្តីប្រកាសព័ត៌មាន</u>
## កម្ពុជា និងជប៉ុន នឹងពង្រឹង និងពង្រីកទំនាក់ទំនង

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំកម្ពុជា បានសម្តែងនូវសេចក្តីពេញចិត្តចំពោះទំនាក់ទំនងរវាងប្រទេសទាំងពីរនាពេលបច្ចុប្បន្ន និងបានចែករំលែកការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យស៊ីជម្រៅទំនាក់ទំនង នៅក្នុងអំឡុងពេលដែលឯកឧត្តមឯកអគ្គរាជទូតចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៣។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញដោយក្តីសោមនស្សរីករាយអំពីការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់នានា នៅក្នុងឆ្នាំ២០២២ រួមមាន ទស្សនកិច្ចរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រី** FUMIO Kishida សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តមរដ្ឋមន្ត្រីការបរទេស HAYASHI Yoshimasa ឯកឧត្តមអតីតរដ្ឋមន្ត្រីការពារជាតិ KISHI Nobuo និង ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ជាដើម។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានសេចក្តីរីករាយដែលកត់សម្គាល់ឃើញថា មិត្តភាព និងកិច្ចសហប្រតិបត្តិការពហុវិស័យរវាងប្រទេសទាំងពីរ នៅតែរឹងមាំ និងបន្តរីកចំរើន ទោះបីជាមានជំងឺរាតត្បាតកូវីដ-១៩ ក្តី ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈការស្តារពាណិជ្ជកម្មឡើងវិញយ៉ាងរឹងមាំ ជិតដល់កម្រិតមុនពេលមានវិបត្តិជំងឺកូវីដ-១៩ ការវិនិយោគដ៏រឹងមាំ កិច្ចសហប្រតិបត្តិការយោធាដែលត្រូវបានពង្រឹង និងការបន្តការគាំទ្ររបស់ជប៉ុននៅលើគ្រប់វិស័យ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង ឯកឧត្តមឯកអគ្គរាជទូតជប៉ុន បានកត់សម្គាល់ដោយក្តីពេញចិត្តចំពោះការដំឡើងទំនាក់ទំនងទ្វេភាគី ពី «ភាពជាដៃគូយុទ្ធសាស្ត្រ» ទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» នៅក្នុងឆ្នាំនេះ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានថ្លែងអំណរគុណដល់ប្រទេសជប៉ុន ចំពោះជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានផ្តល់មកកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការចូលរួមចំណែករបស់ប្រទេសជប៉ុនក្នុងការជួយកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការផ្តល់វ៉ាក់សាំងចំនួន ១,៣ លានដូស ព្រមទាំងឥណទានសម្បទានចំនួន ៤១៦ លានដុល្លារអាមេរិក សម្រាប់ការស្តារឡើងវិញក្រោយពីជំងឺរាតត្បាតកូវីដ-១៩ របស់កម្ពុជា និងសម្ភារៈវេជ្ជសាស្ត្រ ដទៃទៀត។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានកោតសរសើរចំពោះការឆ្លើយតបភ្លាមៗរបស់ប្រទេសជប៉ុនក្នុងការគាំទ្រដល់គោលដៅ «កម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥» របស់ព្រះរាជាណាចក្រកម្ពុជា ផងដែរ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន បានពិភាក្សាអំពីមធ្យោបាយនានាក្នុងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗ រួមមាន វិស័យពាណិជ្ជកម្ម និងការវិនិយោគ ការកសាងសន្តិភាព ការដោះមីន ការអភិវឌ្ឍធនធានមនុស្ស សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ វប្បធម៌ ចំណងរវាងប្រជាជននិងប្រជាជន និងទេសចរណ៍ ជាដើម។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកអគ្គរាជទូតជប៉ុន ក៏បានចែករំលែកយោបល់ក្នុងការជំរុញការចាប់ផ្តើមឡើងវិញនូវជើងហោះហើរត្រង់រវាងប្រទេសទាំងពីរឱ្យបានឆាប់ ដើម្បីជំរុញវិស័យទេសចរណ៍។

ទាំង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកអគ្គរាជទូតជប៉ុន បានពិភាក្សាគ្នាអំពីការរៀបចំសម្រាប់ដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម ប្រាក់ សុខុន ទៅកាន់ប្រទេសជប៉ុននាពេលខាងមុខ ដែលក្នុងឱកាសនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី នឹងមានជំនួបជាមួយឯកឧត្តមរដ្ឋមន្ត្រីការបរទេសជប៉ុន HAYASHI Yoshimasa បន្ទាប់មកអញ្ជើញចូលរួមកម្មវិធីអាហារពេលល្ងាចផ្លូវការរៀបចំដោយសមភាគីជប៉ុនរបស់ឯកឧត្តម។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏នឹងអញ្ជើញជាអធិបតីក្នុងពិធីជប់លៀងដើម្បីអបអរសាទរខួបលើកទី៧០ នៃទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ រៀបចំឡើងនៅក្នុងស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងតូក្យូ ផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងឯកអគ្គរាជទូត UENO Atsushi ក៏បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរ អំពីការវិវត្តក្នុងតំបន់ និងអន្តរជាតិនាពេលបច្ចុប្បន្ន ខណៈដែលឯកឧត្តមឯកអគ្គរាជទូតបានគូសបញ្ជាក់អំពីការកោតសរសើររបស់ជប៉ុនចំពោះការធ្វើជាប្រធានអាស៊ានឆ្នាំ២០២២ របស់កម្ពុជាប្រកបដោយជោគជ័យ និងការខិតខំប្រឹងប្រែងរបស់ប្រេសិតពិសេសរបស់ប្រធានអាស៊ានក្នុងការជួយមីយ៉ាន់ម៉ាឱ្យវិលទៅរកភាពប្រក្រតីវិញ។ ជាមួយគ្នានោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណប្រទេសជប៉ុន សម្រាប់ការគាំទ្រដល់ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា ផងដែរ៕

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៣